# ការរាប់ពុទ្ធសករាជនៅកម្ពុជា

តាមទស្សនាវដ្ដីកម្ពុជសុរិយាឆ្នាំទី២៩ លេខ៥ ខែឧសភា ព.ស.២៥០០ គ.ស.១៩៥៧ដែលដាក់ថាជាលេខពិសេសនិយាយពីពិធីបុណ្យ ប្រទេសកម្ពុជាយើងប្រារព្ធបុណ្យព.ស.២៥០០ រយៈពេល៧ថ្ងៃ ៧យប់ ពីថ្ងៃអាទិត្យ ១៥កើត ដល់ថ្ងៃសៅរ៍ ៥រោច ខែពិសាខ ឆ្នាំរកានព្វស័ក ព.ស.២៥០០ (១២ដល់១៨ ឧសភា គ.ស.១៩៥៧)។

តាមកាលបរិច្ឆេទប្រារព្ធពិធីបុណ្យដែលបង្ហាញខាងលើ យើងឃើញថាថ្ងៃចុងក្រោយនៃពិធីបុណ្យគឺថ្ងៃសៅរ៍ ៥រោច ខែពិសាខ ឆ្នាំរកានព្វស័ក ព.ស.២៥០០ ហើយត្រូវនឹងថ្ងៃទី១៨ ខែឧសភា គ.ស.១៩៥៧។ តាមកាលបរិច្ឆេទនេះ ព.ស.ស្មើនឹងគ.ស.បូកនឹង៥៤៣ ព្រោះ២៥០០ស្មើនឹង១៩៥៧ថែម៥៤៣។ បើថ្ងៃ៥រោច ខែពិសាខ ព.ស.២៥០០ ត្រូវនឹងគ.ស.១៩៥៧ នោះថ្ងៃ៥រោច ខែពិសាខ ព.ស.២៥៦៣គឺ៦៣ឆ្នាំក្រោយត្រូវត្រូវនឹងគ.ស.១៩៥៧+៦៣=២០២០ ឬស្មើនឹង២៥៦៣-៥៤៣=២០២០។

ប៉ុន្តែតាមប្រតិទិនបច្ចុប្បន្ន ថ្ងៃ៥រោច ខែពិសាខ ព.ស.២៥៦៣ បែរជាត្រូវនឹងគ.ស.២០១៩ទៅវិញ ពោលគឺ ព.ស.ស្មើនឹងគ.ស.បូកនឹង៥៤៤ ព្រោះ២៥៦៣ស្មើនឹង២០១៩ថែម៥៤៤ ពោលគឺមិនមែនថែម៥៤៣ដូចកាលពី៦៣ឆ្នាំមុននោះទេ។ ការខុសគ្នាមួយ(១)ឆ្នាំនេះបង្ហាញថានៅកម្ពុជា បុណ្យព.ស.២៥០០ត្រូវបានប្រារព្ធនៅពេលព្រះពុទ្ធសាសនាមានអាយុគ្រប់២៥០១ឆ្នាំឈានចូល២៥០២ឆ្នាំ បើគិតតាមពុទ្ធសករាជបច្ចុប្បន្នដែលចាប់ពីថ្ងៃ១រោច ខែពិសាខដល់ថ្ងៃដាច់ឆ្នាំគ្រិស្តសករាជស្មើនឹងគ្រិស្តសករាជថែម៥៤៤។ ដោយកាលនោះយើងរាប់យឺត១ឆ្នាំនោះ ហើយទើបក្រោយមកមានការកែតម្រូវដោយដំឡើងលេខពុទ្ធសករាជ១ឆ្នាំដើម្បីឱ្យត្រូវនឹងរូបមន្ត"ព.ស.=គ.ស.+៥៤៤"។ តើការដំឡើងលេខពុទ្ធសករាជ១ឆ្នាំនេះចាប់ផ្ដើមនៅពេលណា?

ខាងក្រោមនេះជាការសាកល្បងស្រាវជ្រាវដើម្បីឆ្លើយនឹងសំណួរខាងលើ។

ការស្រាវជ្រាវរកកាលបរិច្ឆេទនៃការផ្លាស់ប្ដូរពុទ្ធសករាជនេះបានប្រើវិធីចំនួន២ដូចខាងក្រោម៖

១-ពិនិត្យនិងផ្ទៀងផ្ទាត់ឆ្នាំនៃលេខទស្សនាវដ្ដីកម្ពុជសុរិយា ដោយសារទស្សនាវដ្ដីនេះផ្សាយខាងសាសនានិងអក្សរសាស្ត្រ មានកំណើតតាំងពីគ.ស.១៩២៦ នៅមានសេសសល់លេខជាប់ៗគ្នាច្រើន និងមានប្រាប់ខែចេញផ្សាយជាខែរាប់តាមសុរិយគតិនិងមានបញ្ជាក់ឆ្នាំតាមគ្រិស្តសករាជនិងឆ្នាំតាមពុទ្ធសករាជនៅលើក្រប។ ក្នុងការផ្ទៀងផ្ទាត់រវាងឆ្នាំពុទ្ធសករាជនិងឆ្នាំគ្រិស្តសករាជ គ្រិស្តសករាជត្រូវបានយកជាគោលដោយផ្ដោតលើបណ្ដាខែចាប់ពីមិថុនាដល់ធ្នូនៃឆ្នាំនីមួយៗដើម្បីធានាភាពត្រឹមត្រូវនិងឯកភាពក្នុងការរកផលដករវាងពុទ្ធសករាជនិងគ្រិស្តសករាជ ព្រោះពីមុនមកធ្លាប់មានការរាប់ចូលពុទ្ធសករាជថ្មីនៅខែមករាដូចគ្នានឹងឆ្នាំសកលឬគ្រិស្តសករាជ ឬនៅខែមេសាដែលជាខែចូលឆ្នាំខ្មែរ ឬនៅថ្ងៃ១រោច ខែពិសាខដែលនៅក្នុងខែមេសាឬខែឧសភា ដូចមាននៅក្នុងតារាងសម្រង់ពុទ្ធសករាជដែលចុះនៅលើក្របទស្សនាវដ្ដីប្រចាំខែ ពីឆ្នាំទី២៥ត្រូវនឹងគ.ស.១៩៥៣ ដល់ ឆ្នាំទី៤២ត្រូវនឹងគ.ស.១៩៧០ ចុះផ្សាយក្នុងគេហទំព័រ WIKISOURCE ។

២-សង្កេតលើខ្លឹមសារមួយចំនួនក្នុងវចនានុក្រមសម្ដេចសង្ឃ ជួន ណាត និងសំណេរមួយចំនួនរបស់សម្ដេចដែលមានចុះកាលបរិច្ឆេទ ទាំងគ្រិស្តសករាជទាំងពុទ្ធសករាជ។

លទ្ធផលនៃការស្រាវជ្រាវតាមវិធីទាំងពីរខាងលើមានដូចខាងក្រោម៖

១-តាមទស្សនាវដ្ដីកម្ពុជសុរិយាពីគ្រិស្តសករាជ១៩៥៣ដល់គ្រិស្តសករាជ១៩៧០ លេខទាំងឡាយមុនខែកញ្ញាគ្រិស្តសករាជ១៩៦៧សុទ្ធតែចុះពុទ្ធសករាជដែលមានចំនួនលើសគ្រិស្តសករាជតែ៥៤២ឬ៥៤៣ឆ្នាំប៉ុណ្ណោះ។ លេខខែមករា កុម្ភៈ និងមីនា គ.ស.១៩៦៨ ចុះពុទ្ធសករាជព.ស.២៥១១ ពោលគឺលើសគ្រិស្តសករាជ៥៤៣។ លេខខែមេ

សាគ.ស.១៩៦៨ចុះពុទ្ធសករាជ២៥១២ ពោលគឺលើសគ្រិស្តសករាជ៥៤៤។ ទោះជាមានការបាត់ទស្សនាវដ្ដីចាប់ពីលេខខែឧសភាដល់ខែធ្នូ គ.ស.១៩៦៨ក៏ដោយ ក៏យើងអាចសន្និដ្ឋានថាលេខពីខែឧសភាដល់ខែធ្នូ គ.ស.១៩៦៨ចុះព.ស.២៥១២ ព្រោះនៅលើក្របទស្សនាវដ្ដីលេខ៣ឬខែមីនាគ.ស.១៩៦៨ដាក់ថាពុទ្ធសករាជ២៥១១ ហើយលេខ៤ឬខែមេសាគ.ស.១៩៦៨ដាក់ថាពុទ្ធសករាជ២៥១២។ ទស្សនាវដ្ដីលេខចាប់ពីខែមិថុនាដល់ធ្នូនៃគ.ស.១៩៦៩ និងលេខចាប់ពីខែមិថុនាដល់ធ្នូនៃគ.ស.១៩៧០ សុទ្ធតែចុះពុទ្ធសករាជដែលមានចំនួនលើសគ្រិស្តសករាជ៥៤៤។ ឯលេខខែកញ្ញា តុលា វិច្ឆិកា និងធ្នូ គ.ស.១៩៦៧ដែលបាត់នោះទំនងជាត្រូវបានចុះពុទ្ធសករាជ២៥១១ ដើម្បីឱ្យវាស៊ីគ្នាជាមួយលេខខែមករា គ.ស.១៩៦៨ដែលចុះព.ស.២៥១១ ។

ដូច្នេះបើតាមការចុះពុទ្ធសករាជនៅលើក្របទស្សនាវដ្ដីកម្ពុជសុរិយា គេអាចសន្និដ្ឋានថាពុទ្ធសករាជត្រូវបានដំឡើងលេខ១ឆ្នាំពី២៥១០ មក២៥១១នៅខែកញ្ញា គ.ស.១៩៦៧ ។

២-នៅក្នុងវចនានុក្រមសម្ដេចសង្ឃជួន-ណាត និងសំណេរមួយចំនួនរបស់សម្ដេចដែលមានចុះកាលបរិច្ឆេទទាំងគ្រិស្តសករាជទាំងពុទ្ធសករាជ មានខ្លឹមសារដែលទាក់ទងនឹងឆ្នាំពុទ្ធសករាជដូចខាងក្រោម៖

-នៅក្នុងវចនានុក្រមសម្ដេចសង្ឃជួន-ណាត បោះពុម្ពគ្រាទី៥ គ.ស.១៩៦៧ នៅខាងចុងនិទាន(introduction) សម្រាប់បោះពុម្ពគ្រាទី៥ ព្រះអង្គបានចុះកាលបរិច្ឆេទថា"ថ្ងៃទី១០ ធ្នូ ១៩៦៧(ព.ស .២៥១១)"។ តាមកាលបរិច្ឆេទនេះ យើងឃើញថាព.ស.ស្មើនឹងគ.ស.ថែម៥៤៤ដែលស្របគ្នានឹងការរាប់ពុទ្ធសករាជបច្ចុប្បន្ន។ ក្នុងការពន្យល់ពាក្យ"ពុទ្ធសករាជ"នៅក្នុងមេពាក្យ"ពុទ្ធ" វចនានុក្រមបានប្រាប់ឱ្យដឹងថាពុទ្ធសករាជថ្មីរាប់ចាប់ពីថ្ងៃ១រោច ខែពិសាខរៀងរាល់ឆ្នាំ។

-នៅក្នុងសៀវភៅស្នាព្រះហស្តក្រោយបង្អស់នៃសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត បោះពុម្ពឆ្នាំ១៩៧០ សម្ដេចជួន-ណាតបានចុះកាលបរិច្ឆេទនៅខាងចុងអត្ថបទមួយចំនួនជាសំណេរផ្ទាល់ព្រះហស្តរបស់ព្រះអង្គដោយមានឆ្នាំជាគ្រិស្តសករាជផងនិងជាពុទ្ធសករាជផង ក្នុងនោះ អត្ថបទសរសេរក្នុងខែកក្កដា តុលា និងធ្នូ គ.ស.១៩៦៨ និងខែមករា គ.ស.១៩៦៩ត្រូវបានចុះព.ស.២៥១២។ នៅក្នុងសៀវភៅដដែលនេះដែរ នៅត្រង់អារម្ភកថារបស់លោក នង-លន់ ដែលជាស្មៀនរបស់សម្ដេចជួន-ណាត មានដាក់កាលបរិច្ឆេទថាថ្ងៃទី៣ មករា ព.ស.២៥១៣ គ.ស. ១៩៧០។

ផ្អែកតាមការចុះកាលបរិច្ឆេទរបស់សម្ដេចសង្ឃជួន-ណាតនិងការពន្យល់អំពីពុទ្ធសករាជនៅក្នុងវចនានុក្រមនិងការចុះកាលបរិច្ឆេទនៅក្នុងសៀវភៅស្នាព្រះហស្តក្រោយបង្អស់នៃសម្ដេចព្រះមហាសុមេធាធិបតីជួន-ណាត បោះពុម្ពឆ្នាំ១៩៧០ យើងអាចសន្និដ្ឋានបានថារូបមន្តពុទ្ធសករាជ"ស្មើនឹងគ្រិស្តសករាជបូកនឹង៥៤៤សម្រាប់រយៈពេលចាប់ពីថ្ងៃចូលពុទ្ធសករាជថ្មីដល់ដាច់ឆ្នាំគ្រិស្តសករាជនីមួយៗ" ត្រូវបានចាប់អនុវត្តចាប់ពីថ្ងៃ១រោច ខែពិសាខ គ្រិស្តសករាជ១៩៦៧ ពោលគឺនៅក្នុងឆ្នាំដែលវចនានុក្រមខ្មែរត្រូវបានបោះពុម្ពគ្រាទី៥។

## ការសន្និដ្ឋាន

ដោយផ្អែកតាមឯកសារទាំងឡាយខាងលើនិងដោយសារវចនានុក្រមនិងស្នាព្រះហស្តសម្ដេចព្រះសង្ឃរាជជួន-ណាតមានលក្ខណៈផ្លូវការនិងសាកលជាងទស្សនាវដ្ដីកម្ពុជសុរិយាយើងសន្និដ្ឋានថាពុទ្ធសករាជត្រូវបានដំឡើងលេខ១ឆ្នាំពី២៥១០ មក២៥១១ចាប់ពីថ្ងៃ១រោច ខែពិសាខ គ្រិស្តសករាជ១៩៦៧ ឬថារូបមន្ត"ពុទ្ធសករាជស្មើនឹងគ្រិស្តសករាជបូកនឹង៥៤៤សម្រាប់រយៈពេលចាប់ពីថ្ងៃចូលពុទ្ធសករាជថ្មីដល់ដាច់ឆ្នាំគ្រិស្តសករាជនីមួយៗ" ត្រូវបានចាប់អនុវត្តចាប់ពីថ្ងៃ១រោច ខែពិសាខ គ្រិស្តសករាជ១៩៦៧ ពោលគឺនៅក្នុងឆ្នាំដែលវចនានុក្រមខ្មែរត្រូវបានបោះពុម្ពគ្រាទី៥។

សម្រង់ពុទ្ធសករាជដែលចុះនៅលើក្របទស្សនាវដ្ដីកម្ពុជសុរិយាពីឆ្នាំទី២៥ត្រូវនឹងគ.ស.១៩៥៣ ដល់ ឆ្នាំទី៤២ត្រូវនឹងគ.ស.១៩៧០

| ឆ្នាំទី | គ.ស. | លេខព.ស.តាមខ្សែឬលេខឬខែ | | | | | | | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១. មករា | ២. កុម្ភៈ | ៣. មីនា | ៤. មេសា | ៥. ឧសភា | ៦. មិថុនា | ៧. កក្កដា | ៨. សីហា | ៩. កញ្ញា | ១០. តុលា | ១១. វិច្ឆិកា | ១២. ធ្នូ | |
| ២៥ | ១៩៥៣ | ២៤៩៥ | ២៤៩៥ | ២៤៩៥ | ២៤៩៥ | ២៤៩៦ | ២៤៩៦ | ២៤៩៦ | ២៤៩៦ | ២៤៩៦ | ២៤៩៦ | ២៤៩៦ | ២៤៩៦ | |
| ២៦ | ១៩៥៤ | ២៤៩៦ | ២៤៩៦ | ២៤៩៦ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | |
| ២៧ | ១៩៥៥ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៧ | ២៤៩៨ | ២៤៩៨ | ២៤៩៨ | ២៤៩៨ | ២៤៩៨ | ២៤៩៧ | ២៤៩៧ | ២៤៩៨ | |
| ២៨ | ១៩៥៦ | ២៤៩៨ | ២៤៩៨ | ២៤៩៨ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | |
| ២៩ | ១៩៥៧ | ២៤៩៩ | ២៤៩៩ | ២៤៩៩ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | |
| ៣០ | ១៩៥៨ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | |
| ៣១ | ១៩៥៩ | ២៥០១ | ២៥០១ | ២៥០១ | ២៥០១ | ២៥០២ | ២៥០២ | ២៥០២ | ២៥០២ | ២៥០២ | ២៥០២ | ២៥០២ | បាត់ | |
| ៣២ | ១៩៦០ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៣ | |
| ៣៣ | ១៩៦១ | ២៥០៣ | ២៥០៣ | ២៥០៣ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | បាត់ | បាត់ | បាត់ | បាត់ | |
| ៣៤ | ១៩៦២ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | ២៥០៤ | |
| ៣៥ | ១៩៦៣ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | ២៥០៥ | |
| ៣៦ | ១៩៦៤ | ២៥០៦ | ២៥០៦ | ២៥០៦ | ២៥០៦ | ២៥០៦ | ២៥០៦ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | |
| ៣៧ | ១៩៦៥ | បាត់ | ២៥០៧ | ២៥០៧ | ២៥០៧ | បាត់ | ២៥០៧ | ២៥០៧ | ២៥០៧ | ២៥០៧ | ២៥០៧ | ២៥០៧ | ២៥០៧ | |
| ៣៨ | ១៩៦៦ | បាត់ | ២៥០៨ | ២៥០៨ | ២៥០៨ | ២៥០៩(១) បាត់ | ២៥០៨ | (២) | ២៥០៩ | បាត់ | ២៥០៩ | ២៥០៩ | ២៥០៩ | |
| ៣៩ | ១៩៦៧ | បាត់ | ២៥០៩ | ២៥០៩ | ២៥០៩ | (២) | (២) | (២) | ២៥១០ | បាត់ | បាត់ | បាត់ | បាត់ | |
| ៤០ | ១៩៦៨ | ២៥១១ | ២៥១១ | ២៥១១ | ២៥១២ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | បាត់ | |
| ៤១ | ១៩៦៩ | បាត់ | បាត់ | បាត់ | បាត់ | (២) | ២៥១៣ | ២៥១៣ | ២៥១៣ | ២៥១៣ | ២៥១៣ | ២៥១៣ | ២៥១៣ | |
| ៤២ | ១៩៧០ | ២៥១៣ | ២៥១៣ | ២៥១៣ | ២៥១៤ | ២៥១៤ | (២) | ២៥១៤ | ២៥១៤ | បាត់ | បាត់ | បាត់ | បាត់ | |

(១)ការដាក់ថា២៥០៩គឺដោយផ្អែកតាមខ្លឹមសារនៅទំព័រ៧៨៦នៃទស្សនាវដ្ដីលេខ៧ ខែកក្កដា គ.ស.១៩៦៦ដែលមានសរសេរថា៖

-នៅថ្ងៃ១៥កើត ខែពិសាខ ឆ្នាំមមីអដ្ឋស័ក ព.ស.២៥០៩(៤.៥.៦៦)

-លុះព្រឹកឡើង ថ្ងៃ១រោច ខែ ឆ្នាំដដែល(៥.៥.៦៦) មានព្រះរាជពិធីដាក់បាត្រព្រះសង្ឃ...

(២)ទស្សនាវដ្ដីនេះបាត់ក្របមុខដែលមានប្រាប់ព.ស.